# ការសំភាសន៍ជាលើកទី២របស់លោកពូ កែវ សុជាតិ

កៈ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា        ខៈ អ្នកដែលត្រូវគេសំភាសន៍ កែវ សុជាតិល

## <u>ការសង្ខេបលើកទី២របស់លោកពូ កែវ សុជាតិ</u>

លោកពូកែវ
សុជាតិនៅក្នុងការសំភាសន៍ជាលើកទី២នេះគឺគាត់បានរៀបរាប់ពីជីវិតរបស់គាត់ពេលដែលគាត់បានទៅធ្វើការនៅប្រទេសថៃហើយគាត់បានធ្វើការនៅលើកប៉ាល់
ហើយមានពេលខ្លះត្រូវធ្វើការមួយយប់ទល់ភ្លឺ
ហើយគាត់ក៏បានវក់នៅក្នុងការញៀនគ្រឿងញៀនដ៏ខ្លាំង
ហើយដោយសារគ្រឿងញៀនគឺជួយអោយគាត់មានកំលាំងនៅក្នុងការធ្វើការ
គឺលើកបាវ៣នៅលើក្បាលក្នុងពេលតែមួយហើយវាមានទំងន់១៥០គីឡូ
នេះដោយសារអំណាចនេះគ្រឿងញៀន។
គាត់បានរត់ចេញពីផ្ទះហើយរស់នៅប្រទេសថៃរយៈពេល២ឆ្នាំហើយគាត់ថាពេលគាត់ស្វាងពីគ្រឿងញៀនគឺគាត់បានគិតថាគាត់ចង់ត្រលប់មកផ្ទះវិញ
ហើយគាត់ក៏គិតថាអោយតំរួតចាប់គាត់ហើយក៏គេចាប់មែន
ហើយគេបានបញ្ជូនគាត់ត្រលប់មកមែនហើយគាត់គ្មានលុយទេ។

កៈជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់លោកពូសុជាតិដែលបានអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិលោកពូជាលើកទី២ហើយហើយនាងខ្ញុំឈ្មោះញ៉ែម
សុគន្ធាជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់លោកពូនៅក្នុងថ្ងៃនេះ
ហើយពួកយើងសំភាសន៍គឺនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៨
ការសំភាសន៍នេះគឺមានទីតាំងស្ថិតនៅក្នុងភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ប្រទេសកម្ពុជា
។អ៊ីចឹងលោកពូពេលមុនញ៉ុមបានសួរខ្លះៗអំពីប្រវត្តិក្រុមគ្រួសារហើយឥឡូវចូលដល់ពីជីវិតលោកពូផ្ទាល់ ក៏ដូចជាការសិក្សារបស់លោកពូអ៊ីចឹងម៉ងហា៎ !!

ខៈបាទ!!

កះឥលូវចូលដល់ការសិ ក្សារបស់ពូមុនសិន អ៊ីចឹងលោកពូលោកពូរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខះរៀនបានថ្នាក់ទី១២ដែរ។

កះហ៊ឺ!!ចប់បាក់ឌុបដែរហេ៎?

ខះអត់បានជាប់ អត់បានប្រលង។

កះម៉េចបានអត់បានប្រលងរៀនបានទី១២ហើយ?

ខះកាលហ្នឹងបានត្រឹមតែប្រលងសាក មុនចូលឆ្នាំ ពេលហ្នឹងញ៉ុមជ្រុលខ្លួនជាមួយមិត្តភក្តិ ពេលហ្នឹងយើងស្រលាញ់ម៉ូតូអាសូនិចហ្នំ
ហើយកាលហ្នឹងមានសមាជិកម្នាក់នៅព្រះវិហារសុខុមស្គាល់ហើយ!!

កះម៉ូតូសូនិចហេ?

ខះបាទ ហើយជំនាន់ហ្នឹងញ៉ុមមានអាគុប អាគុបមូលទេណាស់ តែកាលហ្នឹងគេក៏ជាសមាជិកដែរ គេថាស្រុកគេនៅបាត់ដំបងហា៎ !!ហ៊ឺថានៅបាត់ដំបងម៉ូតូអត់ពន្ធថោកៗច្រើនណាស់ហើយតែ២០០ ៣០០អឺវ៉ាន់ហា៎!! ញ៉ុមក៏នឹកឃើញអញ្ចឹង នឹកឃើញស្រលាញ់ចង់បាន ដល់អាយើងវាភឹបទៅហា៎!!

កះចា៎!!

ខះចិត្តយើងថានេះហ្ន៎!!ដល់ពេលចង់បានក៏លក់ម៉ូតូអ៊ីចឹងទៅ។

កះលក់ម៉ូតូអាគុបមូល?

ខះអាគុបមូលហ្នឹង។

កះបានប៉ុន្មានរយ?

ខះបាន៤០០ ថាទិញគ្រប់ហើយ ស្រាប់ទៅបាត់ដំបងមានទិញមានគ្រប់បានណាទីញបានម៉ូតូថ្លៃចង់ងាប់!!ថ្លៃ។

កះប៉ុន្មានវិញ?

ខះ៧០០ ៨០០ហ្ន៎!!

កះហ៊ឺៗ!!

ខះវាកុហក វាកុហកយើងកាលហ្នឹង ដល់ពេលហើយញ៉ុមមិនដឹងកុហកមិនដឹងម៉េចដែរហា៎!!គេនិយាយអ៊ីចឹងយើងក៏ជឿតាមគេទៅ ទិញអត់បាន ហើយលុយជិតអស់ទៀត បើយើងចូលផ្ទះយើងមានបញ្ហាជាមួយអ្នកផ្ទះ ហើយទៅមកទៅមកអ្នកញ៉ុមទៅជាមួយហ្នឹងគាត់នៅបាត់ដំបងដែរ
គាត់បបួលញ៉ុមទៅថៃទៅប៉ុណ្ណឹង។

កះគាត់ឈ្មោះអីគេដែរពូកម៉ាក់?

ខះអើរហ្នឹងហើយ និយាយពូគាត់ហ្នឹងពូកម៉ាក់ជាមួយពូញ៉ុម គាត់ក៏ដូចជាត្រូវពូកម៉ាក់ដែរចុះ!!កះចា៎!

ខះអាយុប្រហាក់ប្រហាក់ប្រហែលគ្នាហ្នឹង គេហៅគាត់តែបងអឿនបងអឿន ដល់ពេលទៅដល់ហ្នឹងប៉ិបទៅដល់ស្នាក់នៅផ្ទះគាត់ហ្នឹង
ទៅជាមួយគាត់ដែរហ្នឹងហា៎កាលហ្នឹងហា៎!!គាត់ត្រូវត្រូវទៅផ្ទះវិញហ្ន៎!!ក៏ចាយលុយរៀងអស់អី ផងក៏អស់លុយ សល់ប្រហែលជា២០០ បានសល់លុយតែ២០០ ២០០ជាង ដូចប្រហែលជាអស់១០០ជាងពេលហ្នឹងថាដល់ពេលហើយមើលទៅមិនស្រួលដល់ពេលអញ្ចឹងមកផ្ទះមានតែបញ្ហាជាមួយអ្នកផ្ទះអ៊ីចឹងមានតែទៅថៃ អ៊ីចឹ ងទៅទៅទៅ ទៅធ្វើការជាមួយគាត់នៅថៃមួយរយៈហា៎!!!

កះហ្ន៎!!

ខះទៅបានលុយមកវិញទៅសន្សំលុយទៅណាស់។

កះចា៎អ៊ីចឹងហើយ ហ្នឹងហើយពូចុះសំរាប់ អញ្ចឹងដោយសាររៀនដល់ទី១២ហើយតែអត់បានប្រលងបាក់ឌុប?

ខះបាទ បានត្រឹមប្រលងសាក។

កះហ្ន៎!!អ៊ីចឹងពូពេលប្រលងបាក់ឌុបហ្នឹងនៅឆ្នាំណាវិញ?ពេលរៀនថ្នាក់ទី១២ហ្នឹងហា៎?

ខះខ្ទង់ឆ្នាំ២០០០។

កះហ្អ៎!!បើនៅបាន!!

ខះខ្ទង់៩៩(១៩៩៩)២០០០ហ្នឹង។

កះហ្អ៎ខ្ទង់ប៉ុណ្ណឹង។

ខះពីព្រោះញ៉ុមមកវិញឆ្នាំ២០០២ ២០០៣ញ៉ុមចូលធ្វើការរោងចក្រ។

កះចា៎!!

ខះហើយ២០០៣ខែ!!មើល!ញ៉ុមអ់តបានចាំសោះ។

កះភ្លេចម៉ងហោ?

ខះប្រហែលមក២០០២។

កះហ៊ឺ!!

ខះ២០០២ញ៉ុមមកបានប៉ុន្មានខែញ៉ុមធ្វើការរោងចក្រ ដល់២០០៣ ខែ២ញ៉ុមក៏ការប្រពន្ធហ្នឹង ក៏ទៅការប្រពន្ធនៅកំពតហ្នឹង ភាយើងទៅកំដរការ។

កះហ្អ៎ហ្នឹងហើយ!!អ៊ីចឹងពូសំរាប់ពូរៀនបឋមសិក្សាពូរៀននៅសាលាឈ្មោះអីគេ?

ខះសាលាបឋមសិក្សាក្រពើហា។

កះចុះដល់ពេលអនុវិទ្យាល័យ?

ខះសេរីភាព។

កះដល់ពេលឡើងដល់វិទ្យាល័យ?

ខះហ៊ុន សែន តាខ្មៅ។

កះហ្អ៎!!ញ៉ុមខុសពីពូមួយញ៉ុមរៀននៅអនុវត្ត ប៉ុន្តែញ៉ុមអត់ដែលរៀននៅសេរីភាពទេ?

ខះហ្នឹងហើយ។

កះតែញ៉ុមរៀននៅតាខ្មៅ។

ខះហ្នឹងហើយ។

កះហ៊ីនៅក្រពើហាញ៉ុមក៏អត់ដែលរៀនដែរ ។

ខះរៀនដូចគ្នាតែសាលាតាខ្មៅយើង។

កះចាំ!!

ខះតាខ្មៅយើងនេះ។

កះហ្នឹងហើយ ហ៊ីតាខ្មៅញ៉ុមនៅនោះតើ??វិទ្យាល័យហ៊ុន សែននៅនោះ!!

ខះហ្នឹងហើយ តែបឋមហាំ!!

កះបឋមហ្នឹងហើយញ៉ុមអត់រៀននៅហ្នឹងទៅញ៉ុមរៀននៅសាលាបឋមសិក្សាព្រែកហូរ។

ខះហ្ហំព្រែកហូរ!!

កះចាំ!!ហ្នឹងហើយ
អ៊ីចឹងពូសំរាប់ពេលនៅកំពុងសិក្សាហ្នឹងហាំ!!ពូមានដែលមានក្តីស្រម៉ៃថាពូធំឡើងចង់ធ្វើអីគេទេ?

ខះញ៉ុមគោលបំណងញ៉ុមពេលហ្នឹងចង់ធ្វើពេទ្យសត្វ។

កះហូ!!ហើយម៉េច?

ខះតែដល់ពេលទីបញ្ចប់រលាយអស់។

កះហ៊ី!!ដើរខុសមួយជើងពូហោំ?

ខះដើរខុសមួយជើង។

កះចាំ!!អ៊ីចឹងមានអីក្រៅពីពេទ្យសត្វហ្នឹងទៀតទេមានស្រលាញ់អីផ្សេងទៀតទេ?

ខះដូចជាអត់មានទេ។

កះចង់ធ្វើតែមួយហ្នឹងម៉ងហ៎?

ខះបាទ។

កះតែញុំមគិតថាពេលត្រលប់មកវិញចាប់ផ្តើមជាថ្មីក៏មានអីដែរ!!

ខះញុំម!!ខ្លះគេឈប់អីចឹងដែរ គេរៀនគេដាក់ស្វាយរិនចោលគេរៀនយកប្រលង។

កះចាំ!!

ខះគេប្រលងគេធ្វើ គេបានធ្វើការបានធ្វើនគរបាល ពន្ធនាគារខេត្តកណ្តាលគ្រប់គ្នា។

កះចាំ!!

ខះញុំមអត់ ញុំមស្តាយក្រោយដែរយើងមិនគួរ សូម្បីតែរាល់ថ្ងៃញុំមនៅតែគិតថាវាមិនគួរវាមិនគួរអីចឹងហាំ!!

កះចាំ!!មើលទៅដូចជាជីវិតពូដូចជាស្តាយក្រោយច្រើនណាស់ហេ?

ខះបាទញុំមស្តាយច្រើន វាស្តាយកំហុសដែលយើងធ្វើហាំ!!

កះចាំ!!

ខះថាយើងវាមិនគួរធ្វើ យើងប្រព្រឹត្តអិចឹងហាំ!!

កះចាំ!!

ខះហើយជាពិសេសញុំមទៅថៃក៏អីចឹងដែរ ញុំមជាមួយប៊ុនធឿនហាំ ស្គាល់គាត់?

កះស្គាល់ហើយ។

ខះ
ប្រហែលគាត់ស្អប់ញុំមក៏មិនដឹងអីមិនដឹងទេព្រោះអីញុំមគិតក្នុងចិត្តហាំព្រោះអីកូនគាត់ទៅជាមួយយើង តែកូនគាត់ទៅជាមួយយើងហ្នឹងយើងអត់បានហៅទៅជាមួយទេ!!

ក៖ហ្ហ៎!!

ខ៖ញ៉ុមទៅរឿងរបស់ញ៉ុមតែរឿងរបស់ញ៉ុមទេ តែញ៉ុមបានទៅដល់ហ្នឹង២ ៣ថ្ងៃហើយហើយខ្ញុំក៏អត់មានទំនាក់ទំនងអីទៀតដែរ ហើយគេតេទូរសព្ទ័មកញ៉ុមថាទៅណាញ៉ុមថាទៅថៃទេ!!ដល់ពេលវាថាអញ្ចឹងទៅដែរ មិនបាច់មកទេ ញ៉ុមថាមិនបាច់ទេណាស់ស្រាប់តែយប់ឡើងម៉ោងប្រហែលជាម៉ោង៧ ម៉ោង៨វាតេហៅអោយញ៉ុមទៅយកវានៅផ្សារបឹងឈូកហើយញ៉ុមអត់ដឹងអីសោះ!!

ក៖តែឥឡូវគាត់ស្លាប់បាត់ហើយ?

ខ៖ស្លាប់បាត់ហើយ ហើយទៅថៃក៏ធ្វើបាបញ៉ុមច្រើនដែរប៉ុនធឿន ញ៉ុមប្រាប់ប៉ុនធឿនធ្វើបាបញ៉ុមខ្លាំងណាស់។

ក៖ធ្វើបាបម៉េចដែរពូ ?

ខ៖ធ្វើបាបខ្លាំងមែនទែនម៉ងប៉ុនធឿន រឿងជក់រឿងអីទិញមកមិនថាគេនាំទេណាស់ ចេញមកនិយាយទៅចេញមកពីខ្លួនយើងដែរ។

ក៖ហ៊ឺៗ!!

ខ៖ញ៉ុមប្រដៅគេគេក៏អត់ស្តាប់។

ក៖ដល់ពេលអ៊ីចឹងទៅទាំងពីរនាក់ម៉ងទៅ??

ខ៖បាទ!!គេមានលុយ គេអត់មានលុយគេមិនគិតដូចយើងទេណាស់ ដល់ពេលគេអត់លុយមកយើង ប៉ុនធឿនញ៉ុមនិយាយយទៅកាលទៅថៃ ជាងម៉ែឪទៀតហ្ហ៎!! វាដាក់នោះដាក់ ជក់ជក់ឡើងធ្វើការអត់កើត បាយទឹកញ៉ុមរត់ទៅធ្វើបណ្តើររត់ទៅដួសបាយអោយវាស៊ីបណ្តើរចុងជើង ហ៊ីថាពិបាកណាស់។

ក៖ហ្នឹងហើយ ញ៉ុមលឺប្អូនគាត់ប្រាប់ញ៉ុមដែរថា ថាបងគាត់រត់ទៅថៃ។

ខ៖ហ្នឹងហើយ។

កះថាខូចខ្លាំងណាស់។

ខះខូចណាស់ហើយ។

កះហើយឧស្សាហ៍ជិះម៉ូតូដួល។

ខះហ្នឹងហើយ។

កះដួលម៉ង។

ខះនៅជួលកាលញ៉ុមឡើងធ្វើមេហ្នឹងហា៎ ធ្វើមេការ ញ៉ុមអាធឿន ហាអាតាក់ មិនហៅអាធឿនទេហៅអាតាក់ហ្អែងមក!!មកជាមួយយើងទៅណាស់។

កះចា៎!!

ខះវាអត់ទេវាទៅជួយគេអ្នកក្រៅហ្ន៎!!វាអោយនេះទៅណាស់ ដល់ទីបញ្ចប់ ហើយនិយាយទៅលុយកាក់អីយកតែរបស់ញ៉ុមចាយរហូត លុយសន្សំអីវ៉ាន់យកចាយចាយមិនដឹងអីណាអីទេ។

កះចា៎ហ្នឹងហើយ។

ខះបាទទីបញ្ចប់ម៉ាក់វាចោតលើយើងហ្ន៎!!

កះចា៎!!

ខះដូចថាយើងនៅកាលមុនទៅថៃក៏អ៊ិចឹងដែរ យើងមានម៉ូតូ វាអត់ទាន់មានម៉ូតូកាលហ្នឹងហា៎!!កះហ៊ីៗ!!

ខះយើងមានម៉ូតូតាំងពីនេះហ្ន៎!!យើងមានម៉ូតូវាអត់មានម៉ូតូទេ ដល់ពេលយកម៉ូតូយើងជិះទៅណាទៅណីអ៊ិចឹងសួរទៅដើរជាមួយយើងអ៊ីចឹងវាថាយើងអ្នកនាំដើរតាមពិតយើងអត់ដឹងរឿងអីសោះ មិនជឿចាំសួរសុខុម សួរប៊ុនធឿន ។

កះចា៎!!

ខះថាពិបាកណាស់មនុស្សអាតាក់ វាចូលចិត្តលើកចោតតែដាក់គេ។

ក៖ចោតទៅលើគេហោ?

ខ៖បាទ!!

ក៖អ៊ីចឹងពូសំរាប់ការសិក្សាហ្នឹងពូមានដូចអើរសង្ឃឹមថាកូនរបស់ពូអាចបំពេញក្តីស្រម៉ៃរបស់ពូក្លាយជាពេទ្យសត្វហ្នឹងបានទេ?

ខ៖ប្រហែលជាអត់ដឹងទេ ពិបាកនិយាយដែរ យើងវាមិនអាចទៀងទេ។

ក៖ដូចថាខ្លួនឯងធ្វើមិនបានអោយកូនអ៊ិចឹងហាំ??

ខ៖បាទ!!អត់ទាន់ដឹងព្រោះឥលូវកូនញ៉ុមស្រីរៀនទី៨ហើយនៅសាលាសេរីភាពនេះ។

ក៖ហ្ហ៎ចាំ!!

ខ៖មករៀននៅសេរីភាពនេះអត់រៀននៅកំពតទេ។

ក៖ចាំឥឡូវនិយាយពីក្រុមគ្រួសារសិនចុះ
ហើយឥឡូវនិយាយពីជីវិតអាពាហ៍ពិពាហ៍ហើយចាំដល់កូន!!

ខ៖បាទ!!

ក៖អ៊ីចឹងពូរៀបការជាមួយភរិយាឈ្មោះអីគេដែរ?

ខ៖ហ៊ឹម ប៉ុស។

ក៖ហ៊ឹម ប៉ុស?

ខ៖បាទ!!

ក៖ចាំ!!ហើយឥឡូវប្រពន្ធអាយុប៉ុន្មានហើយ?

ខ៖ប្រពន្ធញ៉ុម ដូចឆ្នាំនិយាយទៅដូចឆ្នាំដំណាលៗគ្នា។

ក៖៣៨ដូចគ្នាហ្នឹងហោ៎ឥឡូវហ្នឹង?

ខ៖បាទបាទ!!

កៈចុះគាត់ឆ្នាំខ្មែរកើតឆ្នាំអីគេ?

ខៈឆ្នាំរកដែរ។

កៈហ៊ីរករក!!

ខៈបាទ!!

កៈខ្លាំងៗណាស់ពូហោ?

ខៈវាត្រូវហើយដូចគ្នាមែនទែន ឌីឌីដាក់គ្នាណាស់ អ៊ិចឹតងបានញ៉ុមមិនសូវនៅជិត បើនៅជិតគ្នារវល់តែមានបញ្ហារឿងរ៉ាវ ប្រពន្ធញ៉ុមធ្វើការយឺតហើយហើយអត់ចេះអក្សរ យើងថាធ្វើអញ្ចេកត្រូវ ធ្វើអញ្ចេកត្រូវ គេថាអត់ត្រូវទេ យើងនិយាយទៅគេថាយើងហ្នឹងនិយាយច្រើនទៀត!!រករឿងឈ្លោះជាមួយគេ។

កៈហ្នឹងហើយ។

ខៈពិបាកនិយាយជាមួយគ្នាណាស់!!

កៈចា៎!!អ៊ីចឹងពូសំរាប់ការសរសេភាសាខ្មែរ សរសេរហើយអាន ពូសរសេហើយអានបានរិលទាំងអស់ម៉ងហោ?

ខៈបាទបាន!!

កៈចា៎ដោយសាររៀនដល់ទី១២ហើយ។

ខៈបានគ្រាន់តែថាយើងដឹងពីប្រវត្តិសាស្រ្តទាំងអស់ ទាំងមេរៀនអីដឹង ដឹងច្រើនទាំងអស់ហ្នឹង ជាពិសេសចំនេះដឹងទូទៅ។

កៈចា៎!!

ខៈរបៀបរបបហា៎!!បាទ!

កៈចា៎!!ឥឡូវពូសំរាប់នេះហា៎និយាយពីប្រវត្តិស្នេហារបស់ពូជាមួយប្រពន្ធថីបានជួបគ្នាថីបាន រៀបការជាមួយគ្នា?

ខះអត់ទេប្រពន្ធ និយាយទៅគោលបំណងរបស់ញ៉ុមចង់និយាយថាអត់យកទេប្រពន្ធហ្នំ កាលហ្នឹងញ៉ុមការអាយុ២០ជាងហ្នឹង កាលញ៉ុមនៅទូចៗហាំ កាលញ៉ុមរៀននៅបឋមហ្នឹងអត់ទេ អាយុ៣០ ៤០បានយក៣០ជាងបាននេះហាំតែទីបញ្ចប់ក៏ខុសដែរមកការការ២០ជាងនេះ ញ៉ុមក៏ខុសដែរ។

កះហើយម៉េចបានជួបគ្នាប្រាប់មើល??

ខះដូចកាលហ្នឹងធ្វើការ កាលហ្នឹងញ៉ុមមកទៅ ញ៉ុមធ្វើការបណ្ដែតនៅរោងចក្រអឹម វែនេះរោងចក្រហ្នឹង!!

កះចាំស្គាល់។

ខះនៅរោងចក្របណ្ដែតហ្នឹង ដល់ពេលហើយទៅចុះឡើងៗគេបង្អាប់ចុះបង្អាប់ឡើងក៏ឃើញទៅណាស់ ហើយក៏សួរគេមួយម៉ាត់ទៅ ចុះថៃ ថៃមានគូរដណ្ដឹងនៅអីនៅ?

កះលែបខាយគេដែរហ្នឹងពូឯង??

ខះអត់ទេ មានតែគេទៅសួរអោយញ៉ុមឃើញស្រីខ្លាចណាស់អត់ហ៊ានទេ បើថាបើផឹកអីនេះ!!ហើយគេថាអត់មានអីអឺចឹង ហើយពេលហ្នឹងញ៉ុមទឹមចូលបាន!!និយាយទៅស្នេហាញ៉ុមអត់នេះគ្នាទេ ទោះជាថាចូលនិយាយស្ដីគេ ស្ដីដណ្ដឹងគេក៏អត់បានដើរជាមួយគ្នា ដល់ថ្ងៃការ ការជាមួយគ្នាម៉ង ដល់ការហើយក៏នៅជាមួយគ្នាទៀត ដូចមិនដឹងម៉េច ដូចមិនសូវវានេះហាំដូចវា!!

កះពូខ្លាចៗហេ?

ខះដូចជាថាខ្លាចខ្លាចក៏ថាបាន។

កះចាំ!!ហ្នឹងហើយ អឺចឹងក៏ចាប់ផ្ដើម ដល់ពេល!សួរដឹងថាស្រលាញ់គ្នាទៅវិញទៅមក !!

ខះបាទ!

កៈប៉ុន្តែដល់ពេលសួរហើយអត់ដែលទៅណាទៅណីជាមួយគ្នាទេ??

ខៈអត់ដែលនេះនិយាយតាមត្រង់។

កៈដល់ថ្ងៃការបានការជាមួយគ្នាម៉ង?

ខៈបាទ!!ហ្នឹងហើយ។ដើរម្តងដែរកាលហ្នឹងបុណ្យអុំទូក
បុណ្យអុំទូកយើងហ្នឹងដើរក៏មិនមែនដើរជា២នាក់ដែរ
ដើរបងប្អូនគេមួយរ៉ូងគ្នាយើងក៏មួយរ៉ូងដែរ មិត្តភក្តិញ៉ុម២
៣នាក់ទៀតដើរទៅហើយបន្ទាប់មកក៏អត់មានអីណាដែរ មកផ្ទះយើងវិញមក។

កៈចាំអីចឹងបានដើរជាមួយគ្នាម្តងហ្នឹងមុនការ?

ខៈបាទ!!ផ្ទះជួលគេនៅនេះនៅយើង អឹម វ៉ែហ្នឹង!!

កៈចាំ!!

ខៈរោងចក្រអឹម វ៉ែហ្នឹង។

កៈហ្នឹងហើយ។

ខៈអត់មានដែលនិយាយទៅអត់មានដែលស្គាល់ចិត្តគ្នាទៅវិញទៅមកអត់ដឹងសោះ!!

កៈចុះឥឡូវស្គាល់ចិត្តគ្នាច្រើននៅ?

ខៈស្គាល់ហើយ។

កៈកូន២ហើយពូណោះ?

ខៈបាទ!!ញ៉ុមស្គាល់ចិត្តគេតែគេអត់ស្គាល់ចិត្តញ៉ុម!!

កៈហ្ហ៎!!

ខៈបាទគេអត់ដឹងថាចំណង់ចំណូលចិត្តញ៉ុមហូបអីធ្វើអី
តែយើងដឹងចំណង់ចំណូលចិត្តត្រូវហូបអីធ្វើអី ធ្វើអីធ្វើអីអីចឹងហាំ!!

តែចំពោះគេអត់ដឹងថាយើងចូលចិត្តអី ហូបម្ហូបអី សម្លរអី គេអត់ដឹង យើងស្គាល់ចិត្តគេតែគេអត់ស្គាល់យើង។

កះហ្ន៎អីចឹងវិញទៀត?

ខះបាទ!!

កះឥឡូវពូសំរាប់ពូស្តីដណ្តឹងការកូនគេហ្នឹងមានថ្លៃជំនូនអោយខាងស្រីទេ?

ខះអោយតើ!!

កះអោយប៉ុន្មាន?

ខះកាលហ្នឹងស្រុកគេហ្នឹងគេយកតែ១០០០០០០ ជំនាន់ហ្នឹងជំនាន់ឆ្នាំ២០០៣ហ្នឹង។

កះហ្ន៎ពេលហ្នឹងអត់ទាន់សូវច្រើនដូចជំនាន់ឥឡូវរាប់ម៉ឺនទេពូណោះ??

ខះបាទ!!អត់ទេ ហើយឆ្នាំហ្នឹងញ៉ុម១០០០០០០ច្រើនជាគេទៀត!!កះហ្ន៎!!ខះគេឆ្នាំហ្នឹងខាងស្រីគេធ្វើផ្ទះរៀងៗខ្លួន ហើយស្រុកគេហ្នឹងខាងស្រីធ្វើផ្ទះខាងប្រុសធ្វើផ្ទះចូលគ្នាហើយបានគេការហើយគេយកតែ៣០០០០០ ៤០០០០០អស់ហើយ ហើយយើងជូន១០០០០០០ដាច់ហើយធ្វើផ្ទះខ្លួនឯងទៀត ផ្ទះហ្នឹងនិាយយទៅធ្វើតែខ្លួនឯងអីតែខ្លួនឯងអត់មានម៉ែឪណា អត់មានសូវជួយទេ ម៉ែឪខាងគេហាំ!!

កះចាំតែពូពេលហ្នឹងដូចនេះដែរហេ!អើរជីវភាពគ្រាន់បើខ្លាំងណាស់ដែរបាននេះហេ បានមានលុយអោយគេច្រើនអីចឹង?

ខះមិនជាសូវគ្រាន់បើអីណាប៉ុន្មានទេ ដូចថាយើងកាលហ្នឹងយើងក៏ដូចជាខ្វះខាតដែរ ខ្វះខាតដែរព្រោះអីពួកយើងលក់ដីពីក្រពើហាមកបានតែ២៥០០០ទេម៉ែហាំ!!ហើយគាត់មកទិញនេះ២៥០០០ដែរ ហើយគាត់ខ្វះគាត់ធ្វើផ្ទះធ្វើអីទៀតអស់ច្រើនដែរ!!ខ្វះដែរ ខ្វះដែរហ្នឹង។

កះ២៥០០០ដុល្លាហីអី?

ខ៖ហ្នឹង២៥០០០ដុល្លារ។

ក៖ច្រើនហើយអ៊ីចឹង?

ខ៖អត់ទេ ឆ្នាំ២០០៣លក់ដីយើងលក់ដីម៉ែនៅក្រពើហា កាលពីមុនយើងនៅក្រពើហាហ៎!! លក់ពីក្រពើហាមកទិញផ្ទះថ្មនៅរាល់ថ្ងៃហ្នឹង។

ក៖ចា៎!!

ខ៖ធ្វើអស់ច្រើនដែរផ្ទះកាលហ្នឹងហ៎!!ពេលហ្នឹងក៏ខ្វះដែរលុយហ៎!!យើងទៅកាលហ្នឹងធ្វើហ្នឹងក៏ខ្វះលុយដែរតែលុយខ្ចីគេតែក៏មានចំនែករបស់ញ៉ុមដែរព្រោះលុយពូញ៉ុមនៅជប៉ុននោះផ្ញើរអោយញ៉ុមកាលហ្នឹងបាន១០០ ហើយ១០០ហ្នឹងអត់បានកាន់ទេដាក់លុយតុងទីនជាមួយគាត់លេងតុងទីនលុយសន្សំអោយគាត់ទៅណាស់។

ក៖ចា៎!!តែម៉េចៗបានការប្រពន្ធសិនពូណេះ??

ខ៖បាទ!!

ក៖អ៊ិចឹងពូសំរាប់អើរប្រពន្ធពូចរិកម៉េចដែរ?ស្រលាញ់ពូខ្លាំងទេ?

ខ៖ស្រលាញ់តែឆោត ។

ក៖ម៉េចវិញទៅអ៊ីចឹង?

ខ៖ស្រលាញ់ញ៉ុមខ្លាំងអ៊ីចឹងតែគេនិយាយថាអីអាក្រក់ពីញ៉ុមអ៊ីចឹងចាប់ផ្ដើមរករឿងយើងហើយ អត់មានហេតុផលអីទេណាស់ អត់ដឹងអីអាប្ដីខ្លួនឯងសោះហ្នឹងហ៎!!

ក៖ប៉ុនជឿគេហេ?

ខ៖ប៉ុនជឿគេ និយាយថាពូកែជឿគេ គេនិយាយអាក្រក់ពីយើងច្បាស់ករឿងភ្លេតជំនាន់ញ៉ុមធ្វើការញ៉ុមដើរតែជាមួយចិនទេអ៊ីចឹងរករឿងទៀតហើយ
ថាញ៉ុមដើរជាមួយចិននាំគ្នារកតែស្រី ពួកចិនណារកស្រី ដើរជាមួយចិនកុំមុយនីសចង់ងាប់ដើរគ្រាន់បានហូបអីជាមួយវាដើរទៅគ្រាន់បានហូបអីវ៉ាន់ហ្នឹងហ៎
ហើយចិនវាមិនងាយទេដូចកុំមុយនីស នោះជឿគេណាស់!!

ក៖ដើរជាមួយជនជាតិចិន?

ខ៖ដើរមួយជនជាតិចិន។

ក៖ហើយពូចេះនិយាយភាសាចិនដែរ?

ខ៖អត់ចេះទេចិនចេះខ្មែរ
កាលមុនញ៉ុមស្អាតជាងដល់នេះឥឡូវយើងមានជំងឺក្រពះអីតិចៗដែរណាស់។

ក៖ហ្ហ៎!!

ខ៖ក្រពះហើយណាមួយញ៉ុមដេកអត់គ្រប់គ្រាន់។

ក៖ដល់ពេលអ៊ីចឹងរូបរាងកាយទ្រុតទ្រោមទៅ?

ខ៖ហ្នឹងហើយ !!

ក៖ហ៊ី!!

ខ៖ញ៉ុមកាលពីមុនញ៉ុមស្អាតណាស់។

ក៖ហ្នឹងហើយ។

ខ៖សក់ក្បាលញ៉ុមច្រើនតែកាត់ផ្កាថ្កូវទេណាស់។

ក៖ចា៎!!

ខ៖ដូចចិនអ៊ីចឹង ជិះរម៉ក់គេរវល់តែហៅញ៉ុមថាចិនតើ!!

ក៖ហ្នឹងហើយ ភ្នែកពូ។

ខ៖គេច្រឡំថាចិនហា៎!!

ក៖មែនហ្នឹងមុខពូដូចចិនមែន។

ខ៖មុខដូចចិនតើ ដើរទៅណា ដើរតែជាមួយចិនហ្នឹងចេះតែទៅហើយ។

ក៖ចាំ!!អ៊ីចឹងពូពេលរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកមីងមានកូន២នាក់?ខ៖បាទ!!ក៖អ៊ីចឹងកូនបងហើយប្អូនហ្នឹងគាត់ឈ្មោះអីគេខ្លះកូនទាំង២នាក់ហ្នឹង?

ខ៖កូនបងឈ្មោះកែវ ស្រីលក្ខ័!!

ក៖ទី២?

ខ៖ទី២ឈ្មោះកែវ ឧត្តម។

ក៖ប្រុសមួយស្រីមួយ។

ខ៖បាទ!!

ក៖ហ៊ឺ!!ល្អណាស់អ៊ីចឹង!

ខ៖ប្រុសឆ្នាំខាលស្រីឆ្នាំរកា។

ក៖សំរាប់ពួកគាត់ទាំង២នាក់ហ្នឹងមួយកើតឆ្នាំណាមួយទៀតកើតឆ្នាំណាពូ?

ខ៖កូនស្រីគាត់កើតឆ្នាំរកា។

ក៖ឆ្នាំគាត់កើតខ្មែរ មិនមែនឆ្នាំខ្មែរទេ ឆ្នាំយើង!!

ខ៖ឆ្នាំ២០០៥។

ក៖ចុះកូនប្រុសមួយទៀត?

ខ៖កូនប្រុសកើតជំនាន់កោះពេជ្រ២០១២!!

ក៖២០១២ហោ??

ខ៖២០១២ហ្នឹងជំនាន់កោះពេជ្រ។កើតថ្ងៃកោះពេជ្រ
កោះពេជ្រកំពុងតែក្ដុងក្ដាំងកំពុងតែឈឺពោះ គេស្លាប់នៅកោះពេជ្រហ្នឹងឈឺពោះញ៉ុមនៅទីនេះនៅឡើយ គេនៅផ្ទះ ទៅផ្ទះមុនញ៉ុមគេទៅផ្ទះញ៉ុមនៅលេងកោះពេជ្រនៅឡើយ។

កៈនៅកោះពេជ្រគេជាន់គ្នាស្លាប់ហ្នឹង?

ខៈញ៉ុមបិសដែរកាលហ្នឹង មុនក្រោយគ្នាអត់ដល់១ម៉ោងផងហ្នឹង កូនស្រីញ៉ុមកាលហ្នឹងដូចជាឆ្លងទៅខាងហ្នឹងដែរ ញ៉ុំាអីហើយនៅជិតកន្លែងស្ពានហ្នឹងប្រុងថាទៅហើយនឹងដូចចិត្តមិនស្រួលហើយក៏បកមកវិញទៅណាស់!!

កៈចាំ!!

ខៈដោយសារយើងទិញឥវ៉ាន់ទៀតយើងធូន់ឥវ៉ាន់ហាំ!!!

កៈហ៊ឺៗ!!

ខៈបកមកវិញមកផ្ទះអត់ទាន់បានមួយម៉ោងផង មុននិយាយទៅថាមកដល់ផ្ទះមុនមួយម៉ោងគេនោះមុនយើងចុះថាប្រហែលជាកន្លះម៉ោងចុះថាយើងជិះមកថាប្រហែលកន្លះម៉ោងចុះណាស់ និយាយទៅៗបើយើងកុំមកផ្ទះយើងត្រូវដែរ។

កៈត្រូវជាន់នឹងនឹងគ្នាដែរ។

ខៈត្រូវជាន់នឹងនឹងគេដែរបាត់!!

កៈតែអាយុមិនទាន់អស់មិនទាន់ស្លាប់ទេពូណោះ??

ខៈបាទហ្នឹងហើយ ជាមួយកូនស្រីញ៉ុមមីបងគេហ្នឹងម្ដាយញ៉ុមហើយនឹងញ៉ុមទៅហ្នឹង។

កៈតែប្រពន្ធឈឺពោះឆ្លងទន្លេ?

ខៈឈឺពោះពេលគេកំពុងក្ដុងក្ដាំងកំពុងមើលទូរទស្សន៍ កំពុងមើលទូរទស្សន៍ហ្នឹងហ្នុំ!!

កៈហ៊ឺៗ!!

ខៈជិតភ្លឺដែរហើយ!!

កៈចាំ!!

ខៈញ៉ុមឡើងទៅតាំងពីម៉ោង៥។

ក៖ចាំ!!ម៉ោង៤ ៥ញ៉ុមឡើងទៅ ជិះម៉ូតូទៅដល់ទៅ។ហើយក៏គាត់ឆ្លងទន្លេ យប់ថ្ងៃហ្នឹងទៅ?

ខ៖តែអត់ឆ្លងផង!!

ក៖ហ៊ឺម៉េចអ៊ិចឹង?

ខ៖មួយអាទិត្យទៀតបានឆ្លង។

ក៖ហ៊ឺម៉េចអ៊ីចឹង?

ខ៖ញ៉ុមឆ្ងល់ដែរ ឈឺពោះមួយអាទិត្យ យប់ហ្នឹងឈឺពោះហើយយប់ហ្នឹងមួយអាទិត្យ ឡើងមួយអាទិត្យជាងបន្តិចណាស់បានឆ្លង។

ក៖ចាំហ្នឹងហើយ
អ៊ីចឹងពូសំរាប់កូនរបស់លោកពូទាំង២ពូមានអោយគាត់ទៅរៀនទាំង២នាក់ទេ?

ខ៖អោយរៀនទាំង២!!

ក៖ហ្ហ៎!!

ខ៖ស្រីញ៉ុមអោយរៀននៅទីនេះញ៉ុមថាអោយនៅទីនេះទៅអោយម្ដាយញ៉ុមគាត់ជួយផ្ទង់ផ្ដើម មួយទៅណាស់។ក៖ចាំ!!ខ៖ព្រោះវាថ្នាក់ធំវាអាចអស់លុយច្រើន!!
ហើយនេះម៉ាក់ញ៉ុមនេះគាត់មានលុយច្រើន។

ក៖សំបូរលុយ!!

ខ៖បាទសំបូរលុយជាងយើង!!

ក៖ចាំ!!

ខ៖យើងគ្រុនជន។

ក៖គ្រុនជនម៉េចពូ?

ខ៖ចុះអត់សូវមានលុយមិនគ្រុនជន។

ក៖ហ្នឹងហើយ។អ៊ីចឹងពូសំរាប់ជីវិតរបស់ពូនិយាយពីពេលដែលពូទៅថៃតើមូលហេតុអីដែល ទៅថៃបន្ថែមទៀតអ៊ីចឹងទៅណាស់??

ខ៖បាទ!!

ក៖ហើយការរស់នៅក្នុងប្រទេសថៃហើយការធ្វើការហ្នឹងវាម៉េចដែរពូអាចនិយាយរៀបរាប់?

ខ៖ធ្វើការពេលដំបូងពិបាកណាស់និយាយទៅ
ធ្វើការនៅប្រទេសថៃពេលខ្លះយើងចូលម៉ោង៨ព្រឹកដល់ម៉ោង៩យប់បានបានសំរាក។

ក៖៨ព្រឹកម៉ោង៩យប់ម៉េច?ម៉ោង៩ល្ងាចអី?

ខ៖ម៉ោង៩ភ្លឺ។

ក៖ហ៊ុំអាណាធ្វើម្លឹងៗ??

ខ៖អត់ទេយើងធ្វើចូលធ្វើការពីម៉ោង៨ដល់ម៉ោង១២យើងញុំាបាយ។

ក៖ហ្អ៎ធ្វើការយប់អ៊ីចឹងហេ?

ខ៖ធ្វើការថ្ងៃហា ចូលធ្វើការម៉ោង៨ព្រឹកហាំ!!

ក៖ហើយចេញ??

ខ៖យើងចូលធ្វើការម៉ោង៨ព្រឹកម៉ោង១២ថ្ងៃយើងញុំាបាយម៉ោង១យើងចូលធ្វើការម៉ោង១រហូតដល់ម៉ោង៥ ៥ឈប់ញុំាបាយម៉ោង៦ចូលទៀត ដល់ម៉ោង១២ឈប់ញុំាមួយភ្លាតទេ ញុំាបាយប្រហែលជាកន្លះម៉ោងទេ ចូលធ្វើការ កប៉ាល់ដឹកឥវ៉ាន់ ដឹកដូចជាអង្ករ ស្ករសរអីវ៉ាន់ហ្នឹងហាំ!!

ក៖ហ្អ៎!!

ខ៖ស៊ីម៉ងអីវ៉ាន់ហ្នឹង។

ក៖ហើយដល់ម៉ោង៩ព្រឹក?

ខ៖ម៉ោង៩ព្រឹក ជួនកាល២៤ម៉ោង!!

កៈហ៎ាហើយអ៊ីចឹងមានពេលណាដេក?

ខៈអត់មានពេលដេកអ៊ីចឹងហ៎ា!!ជូនណាលការងារប្រញាប់អ៊ីចឹងទៅ។

កៈហើយអ៊ីចឹងមិនងាប់ហ៎ា?

ខៈបាទវាវេទនាណាស់ អ៊ិចឹងបានពេលហ្នឹងបាក់ពីថៃមកវិញតើបាក់ហ៎ា!!

កៈហើយឈប់អត់បានទេចុះ?

ខៈឈប់អត់បាន ឈប់អត់មានអ្នកធ្វើជំនួសយើង។

កៈងាប់បណ្តោយ។

ខៈគេកំនត់ម៉ារបាំង ម៉ានាលរបាំងកប៉ាល់ាហ៎ា!!

កៈហើយពូធ្វើបានប៉ុន្មានខែនៅហ្នឹង?

ខៈញ៉ុមធ្វើបាន២ឆ្នាំ។

កៈហោធ្វើបានយូរម្ល៉េះអ៊ីចឹងមិនស្លាប់បាត់ហើយបើអត់បានគេងផង។

ខៈអត់អីដែរតែយើងបានញុំារៀងគ្រប់គ្រាន់អត់អីទេ!!

កៈហ៊ឺ!!

ខៈអ៊ីចឹងបានមកពីថៃមកចង់ឡប់ខួរក្បាលហើយណាមួយយើងប្រើថ្នាំទៀតយើងប្រើ។

កៈនៅលើទុកហ្នឹងប្រើថ្នាំទៀត?

ខៈបាទ តែថ្នាំថៅកែគេអត់អោយប្រើទេតែយើងលួចប្រើ!

កៈហ្ហ៎!!

ខៈថៅកែហ្នឹងដឹងវ៉ែហើយថៅកែហ្នឹងអាក្រក់ណាស់ គាត់កាចណាស់ ការលេងល្បែងក៏អត់បានដែរ ក៏អត់បានដែរ!!

ក៖ចាំ!

ខ៖តែខូចមកពីយើងទេ!!តែការងារហ្នឹងយើងអត់ប្រើក៏បានដែរ យើងអត់អីដែរហ្នឹង។

ក៖ពិបាកណាស់ពូ!!

ខ៖ពិបាកណាស់ប្រវត្តិល្វីងជូរចត់ណាស់កុំនិយាយ។

ក៖មើលនិយាយថែមទៀតមើលញ៉ុមចង់ដឹង!!

ខ៖បាទ!!

ក៖ទុកអោយកូនចៅពេលក្រោយស្តាប់អីចឹងហាំ!!

ខ៖បាទ អាហ្នឹងការងារធម្មតាទេណាស់ថាយើងនិយាយមិញហ្នឹងហាំ!!ក៖ហ៊ី១!!ខ៖តែអាការងារគេហៅខូរសាលតបា ស្វានហ្នឹងគឺ២៤ម៉ោងគឺអត់ឈប់សោះ!!

ក៖ហ៊ីនិយាយកុហកពេកហើយពូហេំ??

ខ៖អត់កុហកទេ ញ៉ុមនិយាយញ៉ុមនិយាយក្នុងនាមពិតប្រាកដ ចាប់ពីម៉ោង៨សូម្បីតែម៉ោង៨ញុំាបាយដូរគ្នាញុំាបាយអត់មានឈប់១ម៉ោងទៀតអាហ្នឹងខូងប្រញាប់គេហៅខូងស្វានគេហ្នឹងហា!! គឺ២៤ម៉ោងហ្នឹងគឺធ្វើអត់មាននេះទេ!!

ក៖មនុស្សត្រូវការដេកបើមិនដេកម៉េចមានកំលាំងធ្វើការ??

ខ៖ដល់ថ្នាក់ពេលខ្លះឈរអេញ្ចេក!!ឈរងោកហាំ!!

ក៖ហ៊ី!!

ខ៖ហើយដល់ទៅដល់ពេលទៅយើងញ៉ុមប្រាប់អស់ទៅម៉ងហាំ!!ដល់ថ្នាក់ថ្នាំលែងមានប្រសិទ្ធភាពហាំ!!ថ្នាំជំនួយយ៉ាងណាក៏ដោយទប់យើងអត់កើតហា!!នៅតែនេះនៅតែងុយហាំ!!

ក៖ហើយថ្នាំញៀនហ្នឹងមកពីអ្នកណាគេវិញពូ?

ខ៖ថ្នាំញៀនហ្នឹងនិយាយទៅកាលពីមុនដំបូងចេញពីដូចថាមានមេខ្យល់ក្នុងហ្នឹងគេយកទៅអីចឹងហាំ ដូចអ្នកយកទៅមេមេនៅក្នុងហ្នឹងយកទៅ!!

ក៖ហ៊ឺ!!

ខ៖មួយគ្រាប់នៅក្នុងកប៉ាល់ហ្នឹង១០០បាត។

ក៖ហ៊ឺ!!

ខ៖ហើយនៅតាមក្រៅៗមួយគ្រាប់តែ៥០ មួយចំនេញជាពីរ។

ក៖ហើយចុះបើគេចាប់បានមិនងាប់ហើយពូហេ?

ខ៖អត់ដឹងដែរ
ជារឿង!ដូចអ្នកខ្លះចាប់បានដែរនៅថៃចាប់បានមេប៉ុន្មាននាក់ដែរច្រើននាក់ដែរហ្នឹង!!

ក៖ចាំ!!

ខ៖កុំអីញុំមអត់មកថៃទេ
ញុំមឃើញមិត្តភក្តិញុំមមួយវាបែកថ្នាំហ្វ៉ដល់ថ្នាក់ស្លឹកឈើរតើហ្នឹងវាថាស្លឹកឈើហ្នឹងវាំអោយវាមើល ថាវាហ្នឹងអ្នកមានបុណ្យថាដៃវាហ្នឹងមានកងចាក់ មើលបាតដៃវាមានកងចាក់មើលវា។

ក៖ងាប់បណ្ដោយ!!

ខ៖ហើយមានខ្លះទៀតកំពុងតែធ្វើការធ្វើការនៅលើកប៉ាល់ហ្នឹងហិបែកហាក់ទឹកកប៉ាល់ហាក់មកហៃលទឹកមកខាង
អាខ្លះរយ៉ាស់រយ៉ាយដាច់អីប៉ុន្មានថ្ងៃប៉ុន្មានយប់ហ្វ៉បានគេរកឃើញឡើងស្លែកឡើងស្វិតទៅណាស់ ត្រាំទឹកថាគេដេញចាប់ ថាមានច្រើនណាស់ អាខ្លះរត់ៗទៅខ្លះនិយាយម្នាក់ឯងទៅមើលពិបាកមើលទៅដូចមិនស្រួល។

ក៖ហើយចុះម៉េចនាំគ្នានៅតែប្រើទៀតពូអើយ?

ខ៖អត់ដឹង
បើឈប់ប្រើទៅដោយសារគេសប្បាយហើយមើលទៅហាំ!!ដល់ពេលញុំមអស់ជាតិហាំ
ញុំមគិតពិចារណាមើលគិតថាមិនស្រួលទេអញទៅផ្ទះអញវិញ ដាក់បាយជ្រូកក៏បានដែរ
ញុំមគិតអីចឹងហាំ!!ញុំមដល់ថ្នាក់អោយដំរួត
អោយដំត្រួតចាប់មកវិញហាំ!!ដើរអោយដំរួតគេចាប់មកតើ!!

ក៖រត់ហើយហ្នឹងហោ៎?

ខ៖បាទ?

ក៖រត់?

ខ៖អត់រត់ទេញ៉ុមដើរអោយតំរួតចាប់ញ៉ុមមកម៉ង!!

ក៖ដើរអោយគេចាប់អោយពួកតំរួតហ្នឹងចាប់?

ខ៖ហ្នឹងហើយអោយតំរួតចាប់មកវិញ ព្រោះមកអត់មានសោហ៊ុយមកដដែល ចាប់បញ្ជូនមកដល់ហ្នឹង។

ក៖ស្រួលវិញ?

ខ៖បាទស្រួលវិញ បានដំរួតស្រាប់ចាប់មកដល់នេះដល់ ចាប់ហើយគេបញ្ជូន មកដល់រោងផាក ប៉ុស្ដិ៍ប៉ូលីសហ្នំ៎ រោងផាករោងផាកគេហ្នឹងក៏ជួបមិត្តភក្តិញ៉ុមទៀតជួបអាមិត្តភក្តិញ៉ុមមួយហ្នឹង អើរនេះ វាធ្វើការដែរតែធ្វើការខុសកន្លែងគ្នាហាំ!!

ក៖ហ៊ឺ!!

ខ៖ផ្ទះវានៅបាត់ដំបងថ្មគោល ហើយអត់លុយដូចគ្នាហើយទៅដល់នៅជាមួយគ្នាយើងជិតស្និតជាមួយគ្នានៅថៃដែរហ្នំ!!មកដល់មកជាមួយវា មកជាមួយវាប៉ិបដល់ហ្នឹងស្រាប់គេបញ្ជូនមកដល់ប៉ោយប៉ែត មកដល់ផ្សារអាគាកប៉ោយប៉ែតកន្លែងដើមពោធិហ្នឹងមិនគេហ្នឹងមិនដំរួតមិនគេរកលុយគេថាអាណាមានលុយគេអោយចេញមុនគេអ៊ិចឹងហាំ!!ហើយម៉ែឪវានៅថ្មគោល មុនដំបូងវាមានដែរមាននោះ!!មានលុយដែរ កាលហ្នឹងម៉ូតូឌុបគេអោយខ្ញីមានដែរអោយខ្ញីលុយអោយខ្ញីអោយយើងខ្ញីលុយហាំ!!ខ្ញីអោយលុយនគរបាលហើយឌុបយើងទៅផ្ទះទៅហើយឌុបមកយកលុយវិញហាំ!!

ក៖ចាំ!!

ខ៖ឌុបយកទៅផ្ទះហ្នឹងហើយខ្ញីលុយម៉ូតូឌុបហ្នឹងចាយតាមផ្លូវទៀត។

កៈហ៊ីចិត្តល្អទៀត។

ខៈហ្នឹង!!ហើយញ៉ុមប្រាប់ ហូបហ្ន៎ចែកបានច្រើនពីយើងដែរ ហូបនិយាយទៅហូបដូចថាមិនដែលស្គាល់ហូប។

កៈធ្វើការនៅថៃហ្នឹងពិបាកម៉ងពូ?

ខៈពិបាកម៉ងហា៎ ដល់ពេលទៅដល់ហ្នឹងប៉ិបញ៉ុមច្រូតស្រូវ ញ៉ុមចេះច្រូតស្រូវពីបាត់ដំបងហ្នឹង ចេះច្រូតទៅដល់ច្រូតបានប៉ុន្មានទេ ដូចជួយច្រូតវាបានដូចជាកន្លះខែ ច្រូតវាអីវាជួយការងារអីខ្លះដែរ មិនថាយើងអីនេះគេទេណាស់ មកដល់វិញ មកដល់ផ្ទះវិញញ៉ុមថាប្រុងថាសុំឡានគេមកវិញទៀតវិញហ្នឹងហា៎!!
ស្រាប់តែម៉ែឪវាដឹងថាយើងអត់លុយទេអោយយើងមកអោយសោហ៊ុយយើងមកមិនដឹងប៉ុន្មានទេនេះ!!

កៈហើយចុះធ្វើការងារនៅថៃរហូតហើយហ្នឹងអត់មានលុយមកផ្ទះ?

ខៈចុះបើថាយើងឆ្កួតតែជាមួយថ្នាំញៀន !!

កៈហ្ន៎!

ខៈឆ្កួតតែជាមួយអាហ្នឹងហើយហា៎ ហើយអ្នកខ្លះគិតថាទៅថៃគេធ្វើបាប មិនមែនគេធ្វើបាបយើងទេ គឺខ្លួនយើងធ្វើបាបខ្លួនយើង!!និយាយអ៊ិចឹងម៉ង!!

កៈហ្ន៎!!

ខៈយើងខ្លួនយើងធ្វើបាបខ្លួនយើង ថៅកែអត់អោយលុយតែថៅកែថៃអត់ចេះបោកទេ តែបោកតែខ្មែរគ្នាឯង ហើយគ្នាឯងហ្នឹង យើងខ្លួនឯងធ្វើបាបតែខ្លួនឯងទេ ខ្លួនយើងមិនស្រលាញ់ខ្លួនយើង
អញ្ចឹងមានអ្នកណាស្រលាញ់យើងបើយើងមិនស្រលាញ់ខ្លួនយើងផងហ្នឹងហ្នឹងហើយ!!កៈចា៎!!

ខៈមិនមែនព្រះជិះម៉ូតូឌុបមកជួយណា!!

កៈអូខេ អ៊ីចឹងពូ ញ៉ុមឆ្ងល់ការប្រើថ្នាំហា៎!!

ខ៖ហ្នឹងហើយ!!

ក៖ជក់ទៅវា មួយៗអ្នកខ្លះជក់ទៅញៀនខ្លាំងម្ល៉េះ?

ខ៖បើកាលញ៉ុមឈប់ កាលញ៉ុមញ៉ុមប្រលូក២នៅថៃញ៉ុមប្រលូកអាថ្នាំម៉ា អាគេហៅអាយ៉ាម៉ាយ៉ាបាគេនោះអាគ្រាប់ៗហ្នឹងហាំ!!មកដល់ភ្នំពេញញ៉ុមឆ្លូតម្ដងទៀតញ៉ុមឈប់ឆ្អែតយូរហើយហ្នឹងហាំទឹមចាប់ឆ្កូតប្រហែលជាប៉ុន្មានឆ្នាំនេះ!!ឆ្កូតមិនធម្មតា ឆ្កួតជាមួយអាម៉ាទឹកកកហ្នឹង!!កើហ៊ិ!!ខ៖តែអាទឹកកកហ្នឹងអត់សាហាវដូចអាយ៉ាម៉ាទេ អាយ៉ាម៉ាសាហាវជាង
អាយ៉ាម៉ាហ្នឹងសាហាវណាស់នៅថៃហ្នឹងញ៉ុមជក់មួយគ្រាប់ជក់ហើយនឹងហាំឃើញធ្វើការនិយាយទៅធ្វើបាវអីសឹងតែក្រវែងដូចនេះអ៊ីចឹងហាំ!!

ក៖ខ្លាំងម៉ងហោ៎?

ខ៖វាមិនដឹងមកពីណា?ដូចពេលយើងធ្វើយើងធ្វើធម្មតាទេ
ក្រវែងផុយផុយហើយបើឃើញគេធ្វើការវិញញ៉ុមប្រាប់ញ៉ុមទូល៤
៣បាវហ្ហ៎!!ក្បាលញ៉ុមទូលអង្ករ៣បាវ ១៥០គីឡូហ្ហ៎!!

ក៖ចំ!!

ខ៖ទូលរត់ទៀតហ្ហ៎មិនត្រឹមតែហោ។

ក៖សាហាវម៉ងថ្នាំហ្នឹងហោ៎?

ខ៖បាទ ៣បាវអីវ៉ាន់ហ្ហ៎ អីអ៊ីចឹងទូលផុតមួយទំហឹងស្រើៗអីវ៉ាន់ហ្អសាហាវណាស់!

ក៖ហ៊ឺ!!

ខ៖តែនិយាយទៅញ៉ុមក៏រាល់ថ្ងៃក៏ខូចសុខភាពដែរ ខូចឆ្អឹងខូចឆ្អែងហ្នឹងហើយ!!

ក៖ហ្នឹងហើយដោយសារការជក់ម៉ាហ្នឹងធ្វើអោយពូគិតអីទូចៗវិញ!!

ខ៖បាទ!!!

ក៖ចុះឃើញមនុស្សប៉ុន្មានៗទៅពូ?

ខះឃើញធម្មតាដូចយើងដែរ។

កះធម្មតាដូចយើង ប៉ុន្តែកំលាំងម៉ង??

ខះដូចយើងធ្វើអីធ្វើអីអ៊ិចឹងយើងមានកំលាំងធ្វើអញ្ចឹងហ៎ា!!

កះចា៎!!

ខះបាទ!!

កះអ៊ីចឹងដោយសារមួយហ្នឹងជួយអោយពូដើម្បីអោយមានកំលាំងធ្វើការហើយអត់ដេកទៀត?

ខះហ្នឹងហើយ ហើយតាមនិស្ស័យមនុស្សទៀត និស្ស័យមនុស្សហ្នឹងនិស្ស័យមនុស្សហ្នឹងចង់ទៅលេងល្បែងចង់តែលេងល្បែងគិតតែពីល្បែងទេ មនុស្សហ្នឹងជក់ឧស្សាហ៍ គេទៅធ្វើការគេទៅធ្វើការ ដូចញ៉ុមជក់ហើយគិតតែបោកខោអាវខោអាវសឹងតែបោកហើយសឹងតែរហែកអាវហ្វ៎!!មែននិយាយតាមត្រង់!!

កះតែឥលូវលែងហើយហីពូហី ឈប់ប្រព្រឹត្តហើយហី?

ខះលែងហើយឈប់ប្រព្រឹត្ត ឈប់អស់ហើយ តែនៅប្រព្រឹត្តមួយមុខទៀតនៅស្រានេះ តែស្រាហ្នឹងប្រហែលជាកាត់បន្ថយបានហើយតែយើងមិនអាចបង្ខំទាំងអស់ម៉ងបាន។

កះពូអើយកុំធ្វើបាបខ្លួនពេកពូអើយ!!

ខះហ្នឹងហើយ។

កះពេលហ្នឹងមើលទៅសប្បាយមែនតែពូកំពុងធ្វើបាបខ្លួនឯងហើយណាស់!!

ខះបាទ!!

កះសង្ឃឹមថាពូនឹងអត់ទ្រុតទ្រោមខ្លាំងអីវ៉ាន់អ៊ិចឹងចុះ!!

ខះហ្នឹងហើយ។

កះតែសុខភាពឡើងវិញទាន់ពេលវេលាដែលព្រះផ្តល់អោយយើងមានជីវិតនៅលើផែនដីហ្នឹងទៀត!!

ខ៖បាទ!!

ក៖អ៊ីចឹងថៃទាំខ្លួនឯង ថៃទាំរូបរាងកាយ។

ខ៖ហ្នឹងហើយ។

ក៖អ៊ីចឹងពូមានអីបន្ថែមទៀតទេពីជីវិតពូនៅប្រទេសថៃ?

ខ៖ដូចជាអស់ហើយ។

ក៖គ្រាន់តែធ្វើការហើយនឹងជក់ម៉ាននៅវល់ពេញហ្នឹងម៉ងហោ?

ខ៖គេដូចយើង
ដល់ពេលយើងស្វាងមែនទែនទៅគិតទៅនៅអត់កើតទេត្រូវមកនៅខ្មែរវិញហើយ
អោយគេចាប់មកខ្មែរវិញ។

ក៖ហ៊ឺៗ!!តែចេះមកបានជួបពួកម៉ាក់ទៅមកនៅថ្មគោលហ្នឹង
គេអោយលុយអោយអីធ្វើសោហ៊ុយមកផ្ទះមក!!

ខ៖បាទ!!ហ្នឹងហើយ!!

ក៖ហើយមកដល់ផ្ទះឪពុកម្ដាយម៉េចទៅ?

ខ៖អរសប្បាយដែរតើដំបូងឡើង!!ថាមកដល់ផ្ទះអត់ហ៊ានចូលផ្ទះទេណាស់!!ញ៉ុមមកដល់ដំបូង
ញ៉ុមឈប់ជិះម៉ូតូឌុបញ៉ុមដាក់ឈប់នៅកន្លែងស្ពានថ្ម ហើយផ្ទះសុខុមនៅស្ទឹងជ្រៅ!!

ក៖ចាំ!!

ខ៖ញ៉ុមឈប់នៅអាកន្លែងស្ពានថ្ម
យើងញ៉ុមដើរមកតាមសាលាស្ទឹងជ្រៅមករហូតទៅផ្ទះសុខុមដំបូងបំផុតញ៉ុមមកផ្ទះសុខុមមុន
គេ ហ្នឹងហើយ។

ក៖ពួកម៉ាក់ជិតស្និតបងខុមម៉ង?

ខ៖សុខុមជាងគេ ខុម ភា ខុមជាងគេជិតស្និត។

ក៖ចាំ!!

ខ៖តែខុមហើយចេញពីផ្ទះខុមហ្នឹងមកបានចេញខ្ញីកង់ខុម
ហើយកាលហ្នឹងប្អូនញ៉ុម២នាក់ហ្នឹងវាធ្វើការវិហារ
ដល់ពេលធ្វើការនៅវិហារនៅវ៉ៃឆោរ!!ក៖ចាំ!!ខ៖ជាមួយកូរ៉េហាំ!

ក៖ចាំ!!វិហារផ្សេង?

ខ៖បាទវិហារផ្សេង នៅវិហារផ្សេងគ្នានៅវ៉ៃឆោរ។តែកាលមុនញ៉ុមមកនេះ
នេះកាលមុនវានៅហ្នឹងដែរ
ក្រោយមកមិនដឹងយ៉ាងម៉េចយ៉ាងម៉ានៅនោះទៅជាមួយអ្នកគ្រូចិន្តា អ្នកគ្រូចិន្តានៅនេះស្គាល់?

ក៖អត់ទេ។

ខ៖អ្នកគ្រូចិន្តានៅជិតផ្ទះអ៊ីស្រីឥឡូវទៅនៅអូស្ត្រាលីបាត់ហើយ។

ក៖ហ្ហ៎ស្គាល់ហើយស្គាល់ហើយ។

ខ៖អាចិន្តា។

ក៖បងទូច។

ខ៖ចិន្តាចំណាំជិះអាឆាលី។

ក៖ចាំ!!

ខ៖ហើយពណិសរហាំ។

ក៖ហ្នឹងហើយគាត់ឈ្មោះក្នុងចិន្តានៅខាងក្រៅឈ្មោះស្រីទូច!!

ខ៖ហ្នឹងហើយៗ!!

ក៖ហ្នឹងហើយញ៉ុមនៅទាក់ទងជាមួយគាត់ដែរតើពួកម៉ាក់ជិតស្និតញ៉ុម។

ខ៖គាត់ទៅអូស្ត្រាលី។

ក៖ប្អូនទៅអូស្ត្រាលីបងចិន្តាហ្នឹងនៅនេះនៅអាមេរិកឥឡូវ។

ខ៖ហ្នឹងហោ!

ក៖ញ៉ុមទឹមដើរលេងជាមួយគាត់។

ខ៖មែនទេហី ចិន្តាឪគាត់ធ្វើមុនលក់មាសនៅផ្សារតាខ្មៅណាស់!!

ក៖អូរប្រហែលជាមិនមែនទេអ៊ីចឹង។

ខ៖មែនទេ!!លក់មាសនៅផ្សារតាខ្មៅ។

ក៖ហ៊ីអញ៉ឹមមិនមែនទេប្រហែលអ្នកផ្សេង។

ខ៖មានមួយទៀត ខាងផ្ទះខាងនោះ ខាងផ្ទះកូនអ៊ំណានៅអាមេរិក អ្នកវិហារដែរ។

ក៖ដោយសារចិន្តាបងហ្នឹងហើយ។

ខ៖ចិន្តាបងបង្កើតរបស់គាត់ឈ្មោះបងច្រឹបបងច្រឹប ។មិនមែនទេ!!

ក៖មែនទេ អ៊ីចឹងផ្សេងគ្នាទេ!!

ខ៖ប៉ាគាត់លក់មាស។

ក៖មិនមែនទេអ៊ីចឹងហ្អ៎ពូ!!

ខ៖បាទ!!

ក៖អ៊ីចឹងពូសំរាប់នៅក្នុងប្រទេសខ្មែររបស់យើងហាសង្គ្រាមតែងតែកើតមាននៅជំនាន់ប៉ុលពតនឹងជំនាន់លន់ នល់អីហ្នឹងហោ?

ខ៖បាទបាទ!!

ក៖ចា៎!ពូធ្លាប់ឮអីគេខ្លះនឹងរៀនអីគេខ្លះពីជំនាន់សង្គ្រាមនឹងដែរ?តើពូធ្លាប់ឮអីដែរពូអាចនិយាយអីដែលពូបានដឹងអ៊ីចឹងហា៎សំរាប់សង្គ្រាមហា៎??

ខ៖សង្គ្រាមនិយាយទៅធ្វើអោយយើងស្លាប់អោយយើងបែកបាក់អោយយើងហិនហោច។

កៈហ្នឹងហើយ តែសំរាប់ជីវិតឪពុករបស់ពូម្ដាយរបស់ពូតើគាត់ឆ្លងកាត់អីគេខ្លះ តើពូគាត់ដែលប្រាប់ពីរឿងហ្នឹង?

ខៈឆ្លងកាត់ពិបាក ដូចថាគាត់ជំនាន់ធ្លាក់គ្រាប់អីហ្នឹង និយាយទៅពិបាក។កៈចាំ!!ខៈរត់ពីមួយទៅមួយអីចឹងទៅ!!

កៈចាំអីចឹងពូធ្លាប់រៀនអីគេខ្លះពីសង្គ្រាមប៉ុល ពតតើវាមានរឿងអីគេខ្លះ?

ខៈប៉ុល ពតដូចថាសាហាវកាប់សម្លាប់មនុស្សយើង អត់អោយហូបឆ្អែត ។

កៈចាំ!!ហ្នឹងហើយ។

ខៈកាប់សម្លាប់ ហ្នឹងហើយបង្ខំអោយធ្វើការអីចឹងទៅហើយនិយាយទៅ និយាយទៅអ្នកចេះដឹងយកទៅវៃចោល យកទៅកសាងវៃចោលហ្នឹង។

កៈហ្នឹងហើយ។មានដែលអ្នកណាគេប្រាប់ពូអីច្បាស់ជាងហ្នឹងពីជំនាន់ប៉ុល ពតអីអត់?ដូចជាជីវិតពួកគេនីមួយៗអីអីចឹងទៅណាស់!!ម៉ែឪគាត់ប្រាប់អីវ៉ាន់អីចឹងណាស់??

ខៈគាត់ប្រាប់ថាពិបាកណាស់និយាយទៅ ពិបាករឿងធ្វើការអីវ៉ាន់ហ្នឹង រឿងធ្វើការ ជាពិសេសហូបមិនឆ្អែត បាទ ហូបមិនឆ្អែតហើយយើងធ្វើការហួសកំលាំង ហើយយកយើងទៅវៃចោលអីហ្នឹងអ្នកចេះដឹងអីវ៉ាន់ហ្នឹង វៃចោលអីវ៉ាន់នេះហ្នឹង។

កៈពិបាកណាស់ពូជំនាន់ហ្នឹងណោះ?

ខៈបាទ!!តែញ៉ុមស្រលាញ់ជំនាន់ហ្នឹងដែរ បើធ្វើនេះអីនេះអោយហូបឆ្អែតអីឆ្អែតល្អវិញ។

កៈម៉េចអីចឹង?

ខៈព្រោះសិទ្ធស្មើគ្នា ពាក់ខោអាវខ្មៅដូចគ្នាទៀតហ្នំ ស្បែកជើងស្បែកជើងខ្មៅដូចគ្នាតែណាស់តែម្យ៉ាងគឺអត់អោយហូបឆ្អែត។

កៈហ្នំតែបើអោយហូបឆ្អែតអោយហូបអីត្រឹមត្រូវស្រួលប្រួលស្មើគ្នាទាំងអស់ពូចូលចិត្តវិញ?

ខៈបាទហ្នឹងហើយ ព្រោះអីចំនុចស្មើគ្នា !!ដូចយើងឥឡូវឃើញទេអ្នកមានអ្នកក្រខ្ពស់ទាប ពិបាក ប្រកាន់វណ្ណៈរើសអើង!!

ក៖ចាំ!!ដល់ពេលជំនាន់ហ្នឹងស្មើ?

ខ៖ស្មើ!!

ក៖តែគ្រាន់តែវាពិបាកមួយ អត់អោយហូបហើយនឹងសម្លាប់?

ខ៖ជំនាន់ហ្នឹងកាប់សម្លាប់ហ្នឹងហើយ កាប់សំលាប់ហើយធ្វើអីចឹង។

ក៖ពូចម្មតាសង្គមតែងតែមានខ្ពស់ទាប!!

ខ៖ការប្រែប្រួល!!

ក៖ប្រែប្រួលអីចឹងហើយ!!

ខ៖បាទ!!

ក៖ដោយសារអ្នកខ្លះគេរៀនពូកែគេបានធ្វើធំ!!

ខ៖បាទ!!

ក៖អ្នកខ្លះរៀនអត់ពូកែបានធ្វើតូចទៅ!!

ខ៖ហ្នឹងហើយ!!

ក៖អីចឹងវាត្រូវតែមានឋានៈហើយពូណោះ?

ខ៖តែសង្គមយើងរាល់ថ្ងៃរៀនពូកែក៏ដោយក៏ពិបាកក៏ពិបាកដែរ!!

ក៖ពិបាកអត់មានលុយទាំងអស់!!ខ៖បាទ!!ក៖ហ្នឹងហើយ!!អីចឹងពូមានអីចង់បន្ថែមពីអីហ្នឹងទេ
ដូចពីពូធំឡើងដូចពូដែលលឺអីថាគេទំលាក់គ្រាប់អីបន្ថែមទៀតទេ?ដូចនៅតែមានពួកហ្នឹងតិចតូចៗមកហាំ??

ខ៖មានដែរពួកជំនាន់ខ្មែរក្រហម
ជំនាន់៩៧(១៩៩៧)មានរដ្ឋប្រហារអីវ៉ាន់នោះ!!កាលហ្នឹងមានតើ!!ហ្នឹង៩៧(១៩៩៧)៩៥
៩៦អីហី??ឆ្នាំ៩៧(១៩៩៧)រដ្ឋប្រហារយើងថ្ងៃ៥ ថ្ងៃ៦ ៩៧(១៩៩៧)។

កៈរ៉ៃគ្នាហី?

ខៈរ៉ៃគ្នា៩៧(១៩៩៧)។

កៈហ្នឹងហើយ។

ខៈឆេះផ្ទះឆេះអីវ៉ាន់ហ្នឹង!!

កៈចាំ!!

ខៈស្លាប់មនុស្សស្លាប់អីអស់ច្រើនដែរហ្នឹង!!

កៈចាំ!!

ខៈយើងអីវ៉ាន់ហ្នឹង ថ្ងៃ៥ ថ្ងៃ៦ ៩៧(១៩៩៧)ហ្នឹង។កៈចា!!ខៈក្តុងក្តាំង។

កៈហ្នឹងហើយញ៉ុមអីវ៉ាន់រត់ទៅស្រែហើយពេលហ្នឹងគេថាបាញ់មកដល់តាខ្មៅយើងហ្នឹងហ៎!!

ខៈកាលហ្នឹងញ៉ុមទៅតាខ្មៅហ្នឹង!!

កៈហើយពូមានបានឃើញទេ?

ខៈអត់មានបានឃើញទេព្រោះអីញ៉ុមអត់បានឃើញវាផង។

កៈពូរត់ទៅណាឬក៏នៅតែផ្ទះ?

ខៈនៅតែផ្ទះនៅតាខ្មៅយើងហ្នឹង។

កៈអ់តមានខ្លាចអី?

ខៈអត់ខ្លាច។

កៈចាំហ្នឹងហើយ
អ៊ិចឹងពូមានចង់និយាយអីពូជីវិតបន្ថែមទៀតទេ!!ពូរាល់ថ្ងៃដូចជាពូប្រកបរបរអីចិញ្ចឹមជីវិតដែរ?

ខៈបើញ៉ុមនៅផ្ទះញ៉ុមនៅញ៉ុមដើរទិញអេតចាយ រកអត់សូវបាន
ចាយចុះឡើងចុះឡើងអ្នកទិញច្រើន ហើយវាររល់តែទិញដេញជើងគ្នាអ៊ិចឹង

អត់សូវចំនេញហាំ!! បានញ៉ុមឈប់ទៅបានញ៉ុមមកផ្ទះញ៉ុមវិញមកបោកអ៊ុតជាមួយម្តាយវិញ។

កះហើយគាត់អោយម៉េចដែរលុយ ?

ខះគិតពីគាត់មួយកំផ្លេគិតពាក់កណ្តាលម្នាក់ជាមួយគាត់ហ្នឹង!!

កះហ៊ឺ ហើយគាត់ព្រមទេ??

ខះបាទ?

កះគាត់ព្រមអត់?

ខះគាត់ព្រមតើ!!

កះហ៊ឺ!!

ខះដូចយើងបានមួយកំភ្លេ២០០០ យើងបាន១០០០គាត់បាន១០០០ ហើយគាត់ទឹក!!

កះហើយគិតថាមួយថ្ងៃៗបានប៉ុន្មានកំផ្លេដែរ?

ខះញ៉ុមមិនសូវធ្វើបានច្រើនប៉ុន្មានដែរ កាលពិមុនញ៉ុមបានធ្វើសូវបានធ្វើតែមួយរយៈនេះញ៉ុមមិនសូវបានធ្វើសោះ!!

កះហ៊ឺៗ!!

ខះចេះតែអត់សូវស្រួលអ៊ីចឹងហាំ!!

កះចាំ!!

ខះមិនសូវស្រួល ដូចអត់មិនដឹងម៉េច!!ដូចបាក់ទឹកចិត្តដដូចអីម៉េច!!

កះដូចថាអាសាធាតុពីមុនបន្សល់ទុកឥឡូវទេហេ?

ខះបាទ!!

កះហ្នឹងហើយតែព្យាយានដើម្បីលើកទឹកចិត្តខ្លួនឯងឡើងពូ!!

ខះបាទ!!

កះហើយប្រពន្ធអីវ៉ាន់នៅមូលគ្នាធម្មតាតើហី?

ខះមូលធម្មតាអត់អីទេ!!

កះស្រលាញ់គ្នាទៅវិញទៅមកអីអ៊ីចឹតងដែរហ្នឹងហេ៎??

ខះបាទ!!

កះហ្អ៊
អ៊ិចឹងពូមួយនេះជាសំនួរមួយចុងក្រោយហា៎តើពូមានអីផ្តែផ្តាំទៅកាន់កូនចៅជំនាន់ក្រោយអោយពួកគាត់ដើរលើផ្លូវម៉េចហើយជៀសផុតពីផ្លូវអីគេដែរ?

ខះនិយាយទៅចង់ផ្តែផ្តាំកូនចៅជំនាន់ក្រោយកុំអោយដើរដូចខ្ញុំអ៊ិចឹងហា៎!!
ហើយមុននឹងដើរហើយមុននឹងយើងធ្វើអ្វីមួយ
យើងត្រូវគិតយើងគូរហើយយើងអោយច្បាស់ថាយើងចាំដើរណាស់!!

កះចា៎!!

ខះដូចញ៉ុមថាដើរអ៊ិចឹងអត់មានគំពោងអីត្រឹមត្រូវ ថាត្រូវដើរទេណាស់ តែញ៉ុមដើរផ្លូវហ្នឹងតែទីបញ្ចប់ផ្លូវហ្នឹងគឺខុស ខុសហា៎!!

កះអ៊ិចឹងត្រូវគិតគូរ ។

ខះអ៊ីចឹងមុននឹងដើរផ្លូវហ្នឹងត្រូវគិតគូរអោយបានល្អ ថាផ្លូវហ្នឹងត្រូវដើរទៅល្អឬមិនល្អញ៉ុមដើរទៅញ៉ុមដឹងថាផ្លូវហ្នឹងអាក្រក់ដែរ តែនៅតែផ្តើនដើរ!!

កះហ៊ឺ!!យ៉ាប់ដែរហ្នឹងហេពូហេ??

ខះបាទ!!អ៊ិចឹងកុំយកគំរូតាញ៉ុមហា៎!!
មុននឹងធ្វើអ្វីមួយយើងត្រូវថ្លឹងថ្លែងយើងត្រូវវិភាគមើល!!យើងត្រូវអោយមានប្លង់!!
បើយើងធ្វើអត់មានប្លង់ក៏ពិបាកដែរ ។

កះចា៎!!

ខះនេះគំរោងការនេះប្លង់បាទ!!

កះអ៊ិចឹងពូនៅបន្ថិចទៀត សំនួរមួយទៀត ពេលវេលាអីគេដែលសប្បាយជាងគេសំរាប់ជីវិតរបស់ពូហើយពេលអីគេដែលពិបាកជាងគេគឺជាអីគេសំរាប់ជីវិតរបស់ពូ?

ខះជីវិតកាលសប្បាយជាងគេគឺកាលពេលញុំមសិក្សាញុំមសប្បាយណាស់!!

កះចាំ!ហ្នឹងសិក្សាគឺសប្បាយ??

ខះបាទសប្បាយ។

កះចុះដល់ពេលពិបាកបំផុត?

ខះពិបាកបំផុតដូចយើងមានកូនរាល់ថ្ងៃអ៊ីចឹងគឺយើងត្រូវការលុយអត់លុយអត់កាក់អ៊ីចឹងយើងត្រូវគិតច្រើនណាស់!

កះចាំ!!

ខះត្រូវការគិតនេះគិតនោះហាំ!! កះហ៊ឺៗ!!ខះហើយដល់ពេលណាមួយយើងគិតគិតដល់យើងរាល់ថ្ងៃយើងអាយុយើងច្រើនអ៊ីចឹងយើងអត់សូវមានអីច្រើនដូចគេអ៊ីចឹង មានគំនិតចង់មានចង់បានហាំ!!
អាជំងឺយើងចង់មានចង់បានយើងពីបាកព្យាបាលណាស់!!ជំងឺហ្នឹង
យើងចង់មានចង់បានយើងពិបាកណាស់!!ជំងឺចង់មានចង់បាន
អោយតែមានជំងឺហ្នឹងមួយពិបាកម៉ង!!

កះចាំ!!ដោយសារចង់មានចង់បានតែអត់ដឹងថាត្រូវផ្លូវណាពូហេ?

ខះអត់ដឹងថាត្រូវធ្វើអី!!

កះចាំ!!

ខះយើងដឹងថាត្រូវធ្វើហ្នឹងដែរតែយើងខ្វះដើមត្រូវធ្វើអ៊ីចឹងយើងខ្វះមុខខ្វះក្រោយយើងអត់ធ្វើកើតទេ!!

ក៖ចាំ!!

ខ៖បើគេមានម៉ងគេថាហ្ហធ្វើនោះដឹងតែចំនេញហើយបានហើយគេដាក់ដើមទៅប៉ិបៗ ដឹងតែបានហើយ ហើយយើងមានតែដើមបន្តិចបន្តួច យើងដឹងថាធ្វើនោះវាចំនេញហើយ ថាដើមយើងដាក់បន្តិចបន្តួចទេ
ទៅយើងទៅដល់ដំបូងទៅដល់យើងមានដឹងថាចំនេញណា!!យើងខាតហាំ
សារទី៣បានយើងដឹងថាចំនេញហ្ហ៎!!

ក៖ហ៊ើៗ!!

ខ៖ដំបូងយើងម៉េចឃើញនេះ
ឃើញទេ!!ដល់ពេលហើយអ៊ិចឹងយើងពីបាកនៅត្រង់កន្លែងហ្នឹងទៀតទៅ!!បាទ!

ក៖ចាំ!!ហ្នឹងហើយ
អញ្ចឹងរាល់ថ្ងៃត្រូវប្រហែលពូចាប់ផ្ដើមអញ្ចេះវិញទៅមានតែជួយម្ដាយចាប់ផ្ដើមតែកតក់ៗហ្នឹង ទៅ!

ខ៖ហ្នឹងហើយតែកតក់ៗវិញឥឡូវ!!

ក៖អ៊ិចឹងពូមានពាក្យអីទៀតទេ?

ខ៖ដូចជាអស់ហើយ។

ក៖អស់ហើយអ៊ីចឹងហេ?

ខ៖បាទ!!

ក៖ចាំអ៊ិចឹងអរគុណច្រើនសំរាប់ការសំភាសន៍នៅក្នុងថ្ងៃនេះអ្វីទាំងអស់កូនចៅរបស់ពូនឹងបាន ស្ដាប់សំលេងរបស់ពូអ៊ីចឹងហាំ!!

ខ៖បាទ!!

ក៖នឹងការប្រៀនប្រដៅថាកុំអោយដើរតាមផ្លូវរបស់ពូ!!

ខ៖បាទហ្នឹងហើយ។

កះដោយសារការជក់គ្រឿងញៀនគឺវាបំផ្លាញទាំងខ្លួនឯងបំផ្លាញទាំងសង្គមជាតិគឺអ្វីៗទាំងអស់គឺខ្ទេចខ្ទី។

ខះទាំងកេរ្តិ៍ឈ្មោះទៀត។

កះចាំទាំងកេរ្តិ៍ឈ្មោះ។

ខះជាពិសេសគឺកេរ្តិ៍ឈ្មោះតែម្តង!!

កះចាំ!!

ខះមនុស្សយើងដែលមានលុយច្រើនរាប់តោនបើកេរ្តិ៍ ឈ្មោះយើងអាក្រក់ក៏អត់កើតដែរ។

កះហ្នឹងហើយចាំ!!

ខះបើយើងទៅដល់ណាឈ្មោះគឺអាក្រក់ដូចថាមនុស្ស ដូចសុភាសិតខ្មែរថាដំរីស្លាប់ថាទុកភ្លុកហាំ ខ្លាស្លាប់ទុកស្បែកហាំហើយយើងយើងមិនទុកផងធ្វើម៉េច!!

កះមនុស្សរស់គឺដោយសារកិត្តិយសហ្នឹងណោះ??

ខះកិត្តិយសហ្នឹងហើយ។

កះតែពូអាចស្តារឡើងមកវិញបានទាំងអស់។

ខះបាទ!!

កះហើយម៉េចៗបើមិនស្រួលហ្នឹងបើជក់គ្រឿងញៀនអីវ៉ាន់ហ្នឹងគេចាប់ដាក់គុករាប់ឆ្នាំទៀតហាំពូហាំ!

ខះបាទហ្នឹងហើយ។

កះហើយមានស្រួលអីណានៅក្នុងគុកពិបាកណាស់ជីវិតហាំ!!ខះបាទម៉េចគេហៅគុកមែនគេធ្វើដាក់នេះណាអាហ្នឹង!!

កះមិនស្រួលអាចជិះកង់ទៅនេះទៅនោះបានណាពូ!!គឺនៅតែប៉ុន្មានការេបួនជ្រុងហ្នឹង!!

ខ៖ហ្នឹងហើយ ហើយបើយើងនៅក្រៅយើងចង់ណោះ បើអត់មានលុយច្រើនយើងទិញតែពងទាហ្ងបមួយគ្រាប់ក៏បានដែរអាហ្នឹង ក៏នៅតែមានពងទាហ្ងបកើត!!

ក៖ហ្នឹងហើយ។

ខ៖ទិញបាន ។

ក៖ហ្នឹងហើយ អ៊ិចឹងអរគុណច្រើនណាស់ពូ!!

ខ៖បាទ!!

ក៖សុខសប្បាយ។

ខ៖សុខសប្បាយ។